ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម
សំណុំរឿងព្រហ្មទណ្ឌ
លេខ:២៣៥ ចុះថ្ងៃទី ២២
ខែ មេសា ឆ្នាំ ២០១៨

**សាលក្រម**
លេខ: ២៧ (ក) ចុះថ្ងៃទី
០៤ ខែ មករា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកំពង់ចាមបានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៧ ខែ ធ្នូឆ្នាំ២០១៨ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ប្រធានសាលាដំបូងខេត្តកំពង់ចាម

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

**មេធាវី**

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សារ៉ា ហៅរ៉ាត់ ឈ្មោះ [redacted] ភារម្យ ហៅ រុំ និងឈ្មោះ [redacted] ណី។

**មេធាវី**

-កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ណី។

**ដើម្បីជំនុំជម្រះ**

១-ឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ចាម មុខរបរកសិករប្រពន្ធឈ្មោះ [redacted] ម៉ារី "រ" មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] ទូច "រ" ម្តាយឈ្មោះ [redacted] យី"រ" ជានីតិជនទោសពីមុនគ្មាន ចាប់ខ្លួននៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៨។

២-ឈ្មោះ [redacted] ភារម្យ ហៅ រុំ ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ចាម មុខរបរកសិករ នៅលីវ ឪពុកឈ្មោះ [redacted] អេង "ស" ម្តាយឈ្មោះ [redacted] នាង "ស" ជានីតិជនទោសពីមុនគ្មាន ចាប់ខ្លួននៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៨។

៣-ឈ្មោះ [redacted] ណី ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ចាម មុខរបរកសិករ ប្រពន្ធឈ្មោះ [redacted] សុខ "រ" មានកូនចំនួន០២នាក់ ឪពុកឈ្មោះ



Scanned with CamScanner

[redacted] សុខ ស ម្តាយឈ្មោះ [redacted] វន។ ជានីតិជនទោសពីមុនគ្មាន ចាប់ខ្លួននៅថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១៨។

-ជាប់ចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិដំណាក់អំពិល ឃុំស្តើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលពីថ្ងៃទី១៩ខែមេសាឆ្នាំ២០១៨បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា២១៨នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គិត ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិផ្កាយព្រឹក ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉េងសែ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់រាបក្រោម ឃុំកំពង់រាប ស្រុកកោះសូទិន ខេត្តកំពង់ចាម។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងហ៊ួរ ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិព្រែកដើមចាន់ សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ា ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិប្រធាតុ ឃុំស្រម៉រ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

**<u>អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>**

-កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៨ វេលាម៉ោង០៩យប់ សមត្ថកិច្ចបើកកិច្ចប្រតិបត្តិការចុះបង្ក្រាបករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្លូវលំស្ថិតនៅភូមិដំណាក់អំពិល ឃុំស្តើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដែលបង្កឡើងដោយជនសង្ស័យចំនួន ០៣នាក់ មានឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់ ភេទប្រុស អាយុ២៥ឆ្នាំ ឈ្មោះ [redacted] ភារម្យភេទប្រុស អាយុ២៦ឆ្នាំ និងឈ្មោះ [redacted] ណី ភេទប្រុស អាយុ២៩ឆ្នាំ បានជិះម៉ូតូចំនួន០២គ្រឿង ដោយយកថ្នាំញៀនទៅលក់អោយកំលាំងញុះញង់ឈ្មោះ មី រ៉ា ភេទប្រុស អាយុ២៥ឆ្នាំ ពេលនោះសមត្ថកិច្ចដែលចាំឃ្លាំមើលនៅក្បែរនោះ ក៏បានស្ទុះចូលទៅឃាត់ខ្លួនជនសង្ស័យ០៣នាក់នោះ ក៏បានប្រតាយប្រតប់គ្នា ហើយជនសង្ស័យក៏បានទាញដាវកាប់ទៅលើកំលាំងញុះញង់ និងសមត្ថកិច្ចបណ្តាលអោយរងរបួសចំនួន០៤នាក់ មានឈ្មោះ [redacted] រ៉ា (កំលាំងញុះញង់) របួសកំភួនដៃខាងឆ្វេងដេរចំនួន១១ថ្នេរ ឈ្មោះ [redacted] ម៉េងសែ (នគរបាល) ត្រូវជនសង្ស័យខាំបណ្តាលអោយរបួសដើមដៃស្តាំ ឈ្មោ[redacted] គិត (នគរបាល) របួសចន្លោះម្រាមដៃខាងស្តាំ និងឈ្មោះ [redacted] សេងហ៊ួរ (នគរបាល) របួសដៃខាងឆ្វេង រួចសមត្ថកិច្ចឃាត់ខ្លួនបានជនសង្ស័យទាំង០៣នាក់ខាងលើ រួមទាំងវត្ថុតាងត្រូវបញ្ជូនទៅកាន់អធិការដ្ឋាននគរបាលស្រុកជើងព្រៃ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ៨៤៩ អយ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៥៦៨ ចត ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ



Scanned with CamScanner

២០១៨របស់ប្រធានសាលាដំបូងខេត្តកំពង់ចាម ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់ បានឆ្លើយថា: កាលពីថ្ងៃមិនចាំខែមេសា ឆ្នាំ ២០១៨ វេលាម៉ោង០៩យប់ ឈ្មោះ [redacted] ភារម្យ បានបបួលឈ្មោះ [redacted] ណឺ ទៅមើលល្ខោន ខ្ញុំក៏បានជិះម៉ូតូជាមួយឈ្មោះ [redacted] ភារម្យ ដោយខ្ញុំជិះពីក្រោយ ដោយដៃកាន់ដាវជារបស់ឈ្មោះ [redacted] ភារម្យ ខ្ញុំយកដាវទៅតាមទុកការពារខ្លួន ដោយខ្លាចគេប្លន់ ពេលខ្ញុំជិះមកដល់ផ្លូវតាគេរឈ្មោះ [redacted] ភារម្យ បានឈប់យកថ្នាំញៀនឲ្យគេ ពេលនោះពួកនោះបានចាប់ក្រៀកករខ្ញុំជាប់ចំណែកឈ្មោះ [redacted] ភារម្យ ត្រូវគេចាប់បានដែរ ហើយសមត្ថកិច្ចបានវ៉ៃក្បាលខ្ញុំបុណ្ណាលអោយបែកចេញឈាម និងធាក់ខ្ញុំ ខ្ញុំពុំបានវ៉ៃឬកាប់គេទេ។ សមត្ថកិច្ចបានដកហូតទូរស័ព្ទពីខ្ញុំ០១គ្រឿងមិនចាំម៉ាក និងលុយចំនួន១០.០០០រ (មួយម៉ឺនរៀល)។

-ជនជាប់ចោទឈ្មោះ [redacted] ភារម្យ ហៅ រុំបានឆ្លើយថា: កាលពីថ្ងៃមិនចាំ ខែមេសា ឆ្នាំ ២០១៨ វេលាម៉ោង០៨កន្លះយប់ ខ្ញុំបាទយកថ្នាំទៅអោយគេ ពេលទៅដល់ខាងលិចភូមិដំណាក់អំពិល ខ្ញុំឃើញមនុស្ស០៤ទៅ០៥នាក់នៅកន្លែងល្ងូរ ហើយស្ទាក់ផ្លូវខ្ញុំហើយបានសុំខ្ញុំមើលថ្នាំញៀន ខ្ញុំពុំទាន់បានអោយមើលផង ស្រាប់តែពួកនោះបានចាប់ខ្ញុំជាប់ ចំណែកឈ្មោះ រ៉ាត់ក៏វ៉ៃធ្លាក់ពីលើថ្នល់ ក៏ត្រូវគេចាប់បានដែរ នៅពេលនោះខ្ញុំពុំបានវ៉ៃតបតសមត្ថកិច្ចទេ ហើយខ្ញុំបានស្រែកអោយឈ្មោះ [redacted] ណឺ ជួយផងពីព្រោះគេច្របាច់ករខ្ញុំ ហើយខ្ញុំស្មានតែគេប្លន់ខ្ញុំ នៅពេលគេចាប់ខ្ញុំនោះគេពុំបានប្រាប់ខ្ញុំថា គេជាសមត្ថកិច្ចឡើយ ពេលនោះឈ្មោះ [redacted] ណឺ បានជួយខ្ញុំស្រាប់តែពួកនោះបានបាញ់ឈ្មោះ [redacted] ណឺ ហើយឈ្មោះ [redacted] ណឺ បានស្រែកឲ្យអ្នកឡានជួយពីព្រោះស្មានតែគេប្លន់ ហើយអ្នកឡានក៏ចេញមកចាប់ឈ្មោះ [redacted] ណឺ ទើបដឹងថាជាសមត្ថកិច្ច។ ខ្ញុំពុំបានប្រើអំពើហិង្សាតបតទៅសមត្ថកិច្ចទេ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំនោះ បានដកហូតម៉ូតូសេ១២៥ សេរី២០១៤ ពណ៌ខ្មៅ ខៀវ ០១គ្រឿង ជារបស់អ៊ុំឈ្មោះ ជីន ចេក ទូរស័ព្ទម៉ាកអាយហ្វូន០១គ្រឿង ទូរស័ព្ទម៉ាកអ៊ិនចុចពិល០១គ្រឿង លុយចំនួន ១៤០.០០០រ (ដប់ បួនម៉ឺនរៀល)។

-ជនជាប់ចោទឈ្មោះ [redacted] ណឺបានឆ្លើយថា: កាលពីថ្ងៃមិនចាំ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល០៧កន្លះ ឈ្មោះ [redacted] ភារម្យ បានបបួលខ្ញុំទៅមើលល្ខោននៅវត្តតាស៊ល្ប៍ ក៏បាននាំគ្នាទៅ ខ្ញុំជិះម៉ូតូម្នាក់ឯង ដោយបានដាក់ដាវចំនួន០១ដើម នៅលើម៉ូតូរបស់ខ្ញុំចំណែកឈ្មោះ [redacted] ភារម្យ បានឌុបឈ្មោះ [redacted] សារ៉ា ក៏បានដាក់ដាវទៅជាមួយដែរ នៅពេលខ្ញុំជិះមកដល់ចុងភូមិដំណាក់អំពិល ខ្ញុំបានឃើញមនុស្សប្រុសចំនួន០៤នាក់ ពាក់អាវស៊ីវិលបាន អង្គុយនិងឈរនៅតាមផ្លូវក្បែរម៉ូតូ ខ្ញុំក៏ជិះហួសទៅប្រហែល៣០ម៉ែត្រ ចំណែកឯឈ្មោះ [redacted] ភារម្យ ក៏ជិះតាមក្រោយក៏ឈប់កន្លែងមនុស្ស០៤នាក់នោះ ពេលនេះខ្ញុំឮសំឡេងប្រតាយប្រតប់គ្នា ហើយក៏ស្រែកអោយខ្ញុំជួយខ្ញុំក៏បកម៉ូតូត្រឡប់មកវិញ ស្រាប់តែមនុស្សប្រុស០៣នាក់ ពាក់អាវស៊ីវិល បាន

ស្ទុះមករកចាប់ខ្ញុំ ខ្ញុំស្មានតែពួកចោរក៏បានដកដាវក្រវាសកុំអោយពួកនោះចូលមកយកម៉ូតូរបស់ខ្ញុំ ពេលនោះក៏មានរថយន្តមកដល់ ខ្ញុំស្រែកឲ្យរថយន្តនោះជួយ ស្រាប់តែពួកនោះបានស្រែកថាឲ្យបើកឡានបុកវាទៅ ខ្ញុំក៏លោតពីលើថ្មល់ខ្លាចឡានបុក ស្រាប់តែពួកនោះបាញ់គំរាមខ្ញុំកុំឲ្យរត់ ខ្ញុំក៏សួរពួកនោះថា បងឯងជាប៉ូលីសមែនឬអត់ បើបងឯងជាប៉ូលីសខ្ញុំប្រគល់ខ្លួនអោយចាប់តាមសម្រួល បន្ទាប់មកខ្ញុំក៏បានប្រគល់ខ្លួនអោយគេចាប់ ស្រាប់តែប៉ូលីសហ្វូរ នៅខេត្តកំពង់ចាមបានទាត់ធាក់ខ្ញុំ និងប៉ូលីសប្រុសមាឌស្តើងប្រជ្រុយដុះ នៅនឹងមុខខាងឆ្វេង ជាអ្នកវាយក្បាលខ្ញុំបណ្តាលអោយបែកចំនួន០២ទៅ០៣ស្នាប់កាំភ្លើងខ្លី និងទាត់ធាក់ខ្ញុំបាទត្រូវឆ្អឹងជំនីរទាំងសងខាងបណ្តាលអោយខ្ទាំពេញខ្លួនប្រាណ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំ បានដកហូតម៉ូតូម៉ាកសេ ១២៥ ពណ៌ខ្មៅ០១គ្រឿងជារបស់ម្តាយខ្ញុំ ទូរស័ព្ទណូគាចុចពិល០១គ្រឿង ដាវ០១ដើម លុយចំនួន ១៥.០០០៛ (មួយម៉ឺនប្រាំពាន់រៀល)។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]រ៉ា បានឆ្លើយថា: កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៨ វេលាម៉ោង២១និង០០យប់ ហើយខ្ញុំបាទទូរស័ព្ទទៅឈ្មោះ ភារម្យ អោយយកថ្នាំមកអោយខ្ញុំ ដោយខ្ញុំបាទទិញតំលៃ២០$ (ម្ភៃដុល្លាអាមេរិក) ដោយណាត់ជួបគ្នានៅលើទំនប់ក្នុងភូមិដំណាក់អំពិល ឃុំស្តើងជ័យ។ ក្រោយមកខ្ញុំបានជិះម៉ូតូជាមួយ កំលាំងសមត្ថកិច្ច០២នាក់ទៅជាមួយពេលនោះឈ្មោះ ភារម្យ បានហុចថ្នាំមកអោយខ្ញុំ ស្រាប់តែកំលាំងសមត្ថកិច្ច បានចាប់ឈ្មោះ [redacted] និងឈ្មោះ [redacted]សារ៉ា បានស្រាប់តែទាំង០២នាក់នេះបានស្រែកអោយឈ្មោះ សុខ ណី ជួយពេលនោះឈ្មោះ [redacted] ណី បានជិះម៉ូតូហួសក៏ត្រឡប់មកវិញ ហើយបានយកដាវ មកក្រវាសត្រូវខ្ញុំចំនួន០១ដាវ ពេលនោះកំលាំងសមត្ថកិច្ចបានជិះឡានមកដល់ឈ្មោះ [redacted]ណីបានរត់ចុះទៅតាមភ្លឺស្រែ ហើយសមត្ថកិច្ចដេញតាមឈ្មោះ [redacted]ណីចំណែកខ្ញុំក៏មកមន្ទីរពេទ្យភ្លាមប្រញាប់ដេរស្នាមរបួស។ ចំពោះឈ្មោះ [redacted] ណី បានរត់យកដាវទៅជាមួយនោះ បានកាប់អ្នកណាទៀត ខ្ញុំពុំដឹងឡើយ។ ចំពោះរបួសខ្ញុំបាទបានព្យាបាលនៅពេទ្រអស់ប្រាក់ចំនួន ៦០០.០០០៛ (ហុកសិបម៉ឺនរៀល)។ សំណូមពរទាមទារប្រាក់ថ្លៃថ្នាំព្យាបាល និងខាតពេលវេលាចំនួន ១.០០០.០០០៛ (មួយលានរៀល)។

-តាមអំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងហ៊ួរ បានឆ្លើយថា: កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៩ វេលាម៉ោង០៩យប់ បទបញ្ជាមេដឹកនាំបានឲ្យចុះបង្ក្រាបករណីជួញដូរគ្រឿងញៀននៅចំណុចភូមិដំណាក់អំពិល ឃុំស្តើងជ័យ ស្រុកជើងព្រៃ ខ្ញុំបាទបានចុះបង្ក្រាប ដោយជិះម៉ូតូមានគ្នា០២នាក់ ទៅដល់កន្លែងណាត់ប្រគល់ទិញលក់ថ្នាំ ក៏ឃើញជនសង្ស័យចំនួន០៣នាក់និងម៉ូតូ០២គ្រឿង តែពុំបានឃើញមានអាវុធនៅនឹងដៃទេពេលភ្នាក់ងាររាយការណ៍ ខ្ញុំបាទក៏ជិះម៉ូតូមានគ្នា០២នាក់ជាសមត្ថកិច្ចដូចគ្នា ពេលដល់កន្លែកកើតហេតុជនសង្ស័យបានហុចថ្នាំញៀនមកអោយភ្នាក់ងារឈ្មោះ [redacted] រ៉ា រួចហើយខ្ញុំបាទនិងកម្លាំងមានគ្នា០៤នាក់ទៀត

ក៏ចាប់ឃាត់ខ្លួនឈ្មោះ [redacted] ភារម្យ និងឈ្មោះ [redacted] សារ៉ា ចំណែកខ្ញុំក៏ទៅឃាត់ឈ្មោះ [redacted] ណឺ តែឈ្មោះ [redacted] ណឺ បានទាញដាវយាកាប់មកលើខ្ញុំ តែត្រូវបានកំលាំងភ្នាក់ងាររងត្រូវកំភួនដៃខាងឆ្វេង តែខ្ញុំពុំបានត្រូវទេ . ពេលនោះមានក្រុមសមត្ថកិច្ចមកដល់ឈ្មោះ [redacted] ណឺ បានរត់ទៅកណ្តាលវាលស្រែ ហើយសមត្ថកិច្ចបានគំរាមអោយទំលាក់ដាវតែឈ្មោះ [redacted] ណឺ មិនព្រមទំលាកទេ ហើយឈ្មោះ [redacted] ណឺ ក៏ឈប់ ដៃនៅយាដាវនៅឡើយ ខ្ញុំចូលទៅចាប់ជាមួយឈ្មោះ ហ៊ា គិត ពេលនោះមានការប្រតាយប្រតប់គ្នា ខ្ញុំបាទក៏ត្រូវឈ្មោះ [redacted] ណឺ លើកដាវក៏មុតដៃខាងឆ្វេង (ម្រាមដៃនាងនិងម្រាមដៃកណ្តាល) បន្ទាប់មកក៏ចាប់បានឈ្មោះ [redacted] ណឺ ដោយឆែកឃើញមានថ្នាំញៀនចំនួន០២កញ្ចប់នៅនឹងខ្លួន ព្រមទាំងដកហូតបានដាវចំនួន០២ដើម និងម៉ូតូ០២គ្រឿង។ ថ្លៃថ្នាំព្យាបាលមេជាអ្នកចេញអោយ។ សំណូមពរសុំទារសំណងចំនួន ១០.០០០.០០០៛ (ដប់លានរៀល)។

-តាមអំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គិត បានឆ្លើយថា: កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង២១និង០០នាទីយប់ ខ្ញុំបាទនៅក្នុងឡាន ហើយក៏លាំងពួកខ្ញុំបានទៅទំនាក់ទំនងទិញថ្នាំញៀន ដោយណាត់ទិញថ្នាំញៀននៅទំនប់ក្នុងភូមិដំណាក់អំពិល ក្រោយមកកំលាំងភ្នាក់ងារបានទូរស័ព្ទថា បានថ្នាំញៀនហើយ រួចហើយពួកខ្ញុំស្លៀកខោអាវស៊ីវិលមានគ្នា០៤នាក់ ពេលទៅដល់កន្លែងទំនប់ ក៏ឃើញកំលាំងសមត្ថកិច្ច បានប្រតាយប្រតប់គ្នាដោយឃើញឈ្មោះ [redacted] ណឺ ភេទប្រុស កាន់ដាវបានកាប់ទៅលើឈ្មោះ [redacted] រ៉ា ចំនួន០១ដាវ ត្រូវដៃខាងឆ្វេង ជាកំលាំងភ្នាក់ងារស្លៀកពាក់ស៊ីវិល ចំណែក០២នាក់ទៀត ខ្ញុំបាទពុំបានដឹងកាន់ដាវឬក៏អត់ទេ។ ក្រោយមកឈ្មោះ [redacted] ណឺ បានរត់តាមវាលស្រែ ខ្ញុំបាទមានគ្នា០៣នាក់ បានរត់ទៅតាមចាប់ឈ្មោះ [redacted] ណឺ ហើយខ្ញុំបានស្រែកថា ឈប់ហ្មែង ឈប់អញបាញ់ឥឡូវ ពេលនោះឈ្មោះ [redacted] ណឺ ក៏ឈប់ខ្ញុំប្រាប់អោយទំលាក់ដាវចុះ តែឈ្មោះ [redacted] ណឺ មិនទំលាក់ដាវឡើយ ខ្ញុំបាទក៏ស្ទុះទៅចាប់ ហើយឈ្មោះ [redacted] ណឺ បានយាដាវមកក៏ត្រូវដៃខ្ញុំបាទខាងស្តាំ ហើយខ្ញុំក៏បានចាប់ជាប់តែម្នាក់ឯង បន្ទាប់មកកំលាំង០២នាក់ទៀត ក៏បានចូលមកជួយ ហើយបានយកមកអធិការនគរបាលស្រុកជើងព្រៃ។ ចំណែកឈ្មោះ [redacted] ភារម្យ ហៅ រុំ និងឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត ពុំបានតបតមកខ្ញុំបាទទេ។ សំណូមពរសុំអោយតុលាការផ្តន្ទាទោសទៅតាមច្បាប់ ខ្ញុំបាទពុំទាមទារសំណងរដ្ឋប្បវេណីឡើយ។

-តាមអំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] .ម៉េងសៃ បានឆ្លើយថា: កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៨ វេលាម៉ោង២១និង០០យប់ នៅចំណុចភូមិដំណាក់អំពិល ឃុំស្ដើងជ័យ ស្រុកជើងព្រៃ ពេលនោះប្រធានអង្គភាព បានឲ្យខ្ញុំបាទចុះទៅបង្ក្រាបករណីជួញដូរថ្នាំញៀន ដោយបានជិះម៉ូតូចំនួន០២គ្រឿង មានគ្នាចំនួន០៤នាក់ ទី១-ឈ្មោះ [redacted] រ៉ា ភេទប្រុសជាភ្នាក់ងារ ទី២-ឈ្មោះ [redacted] គិត ភេទប្រុស អាយុ២៩ឆ្នាំ ជាសមត្ថកិច្ច ទី៣-ឈ្មោះ [redacted] សេងហួរ

ភេទប្រុស ជាសមត្ថកិច្ច និងទី៥របខ្ញុំបាទ បានចុះទៅដល់កន្លែងកើតហេតុជនសង្ស័យ០៣នាក់ ដែលមានម៉ូតូចំនួន០២គ្រឿង បានហុចថ្នាំញៀនចំនួន០២កញ្ចប់ មកអោយឈ្មោះ [redacted] រ៉ា ជាកម្លាំងភ្នាក់ងារ ពេលនោះខ្ញុំបាទក៏ចុះចាប់ឃាត់ខ្លួនបាន០២នាក់ គឺឈ្មោះ [redacted] សារ៉ា និងឈ្មោះ [redacted] ការម្យ។ ពេលដែលខ្ញុំចាប់ឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត នោះខ្ញុំបាទកៀកក ស្រាប់តែឈ្មោះ ទូច សារ៉ា ហៅ រ៉ាត បានខាំដៃខ្ញុំបាទបណ្ដាលអោយរបួសកំភួនដៃខាងស្ដាំ បច្ចុប្បន្នបានជាសះស្បើយហើយ។ ក្នុងរឿងនេះខ្ញុំបាទមិនទាមទារប្រាក់សំណងជំងឺចិត្ត និងថ្លៃព្យាបាលទេ សុំឲ្យតុលាការ មេត្តាសំរេចទៅតាមច្បាប់ចុះ។

-តាមអំណានចំលើយសាក្សីឈ្មោះ [redacted] យាង បានឆ្លើយថា:ចំពោះឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់ ភេទប្រុស ឈ្មោះ [redacted] ការម្យ ហៅ រុំ ភេទប្រុស និងឈ្មោះ [redacted] ណី ភេទប្រុស ជាអ្នកនៅក្នុងភូមិឃុំជាមួយខ្ញុំបាទជាមនុស្សស្លូតបូត សុភាពរាបសារ គោរពចាស់ទុំ ពុំដែលមានទំនាស់ជាមួយអ្នកណាឡើយ ហើយពុំដែលបង្កើតបងតូចបងធំ នៅក្នុងភូមិឃុំឡើយ អ្នកស្រុកនៅក្នុងភូមិតែងតែស្រឡាញ់រាប់អានគ្រប់ៗគ្នា។ ចំពោះអ្នកទាំងបីនាក់នេះ បានប្រព្រឹត្តបទល្មើសនោះខ្ញុំបាទ ពុំបានដឹងឡើយ។

-តាមអំណានចំលើយសាក្សីឈ្មោះ [redacted] បូ បានឆ្លើយថា:ចំពោះឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់ ភេទប្រុស ឈ្មោះ [redacted] ការម្យ ហៅ រុំ ភេទប្រុស និងឈ្មោះ [redacted] ណី ភេទប្រុស ជាអ្នកនៅក្នុងភូមិឃុំជាមួយខ្ញុំបាទ ជាមនុស្សស្លូតបូត សុភាពរាបសារគោរពចាស់ទុំ ពុំដែលមានទំនាស់ជាមួយអ្នកណាឡើយ ហើយពុំដែលបង្កើតបងតូចបងធំនៅក្នុងភូមិឃុំឡើយ អ្នកស្រុកនៅក្នុង ភូមិតែងតែស្រឡាញ់រាប់អានគ្រប់ៗគ្នា។
ចំពោះអ្នកទាំងបីនាក់បានប្រព្រឹត្តបទល្មើសនោះខ្ញុំបាទពុំបានដឹងឡើយ។

-តាមអំណានចំលើយសាក្សីឈ្មោះ [redacted] ជីន បានឆ្លើយចំពោះឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត ភេទប្រុស ឈ្មោះ [redacted] ការម្យ ហៅ រុំ ភេទប្រុស និងឈ្មោះ [redacted] ណី ភេទប្រុស ជាអ្នកនៅក្នុងភូមិឃុំជាមួយខ្ញុំបាទ ជាមនុស្សស្លូតបូត សុភាពរាបសារគោរពចាស់ទុំ ពុំដែលមានទំនាស់ជាមួយអ្នកណាឡើយ ពុំដែលបង្កើតបងតូចបងធំនៅក្នុងភូមិឃុំឡើយ អ្នកស្រុកនៅក្នុងភូមិតែងតែស្រឡាញ់រាប់អានគ្រប់ៗគ្នា។ ចំពោះអ្នកទាំងបីនាក់ បានប្រព្រឹត្តបទល្មើសនោះ ខ្ញុំបាទពុំបានដឹងឡើយ។

## តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន

-នៅពេលសវនាការនេះ ជនជាប់ចោទទាំងអស់បានឆ្លើយសារភាពអស់ហើយ ដោយសមត្ថកិច្ចចុះបង្ក្រាបគ្រឿងញៀន ហើយមានការប្រតាយប្រតប់គ្នា ធ្វើអោយមានរបួសដល់សមត្ថកិច្ច ដោយជនរងគ្រោះបានឆ្លើយបញ្ជាក់ថា គឺជាការក្រវៀសដាវ មិនមែនកាប់ទេ។ ហេតុនេះ ដោយផ្អែកទៅលើភស្តុតាងជនជាប់ចោទទាំងអស់ គ្មានបំណងកាប់ទៅលើជនរងគ្រោះនោះទេ។

ដូច្នេះតំណាងអយ្យការសុំតំកល់សេចក្តីសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំអោយលោកចៅក្រមជំនុំជម្រះមេត្តាពិចារណាទៅលើជនជាប់ចោទទាំងអស់ដែលបានឆ្លើយសារភាព និងដឹងពីកំហុសរបស់ខ្លួន។

## មេធាវី ហៃ សៀវមុី ធ្វើសេចក្តីសន្និដ្ឋាន

-ឆ្លងតាមសវនាការនេះ កូនក្តីខ្ញុំបានឆ្លើយសារភាពអស់ហើយ ដោយកូនក្តីខ្ញុំគ្មានបំណងកាប់ទៅលើជនរងគ្រោះនោះទេ គឺគ្រាន់តែក្រវៀសដាវការពារខ្លួន ស្មានតែចោរប្លន់ ហើយជនរងគ្រោះ ក៏បានឆ្លើយបញ្ជាក់ជូនតុលាការរួចហើយដែរ គឺថាកូនក្តីខ្ញុំគ្រាន់តែក្រវៀសដាវតែប៉ុណ្ណោះ។ ដូច្នេះសុំលោកចៅក្រមជុំនុំជម្រះ មេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទ ដោយក្តីអនុគ្រោះ។

## មេធាវី នៅ រក្សា ធ្វើសេចក្តីសន្និដ្ឋាន

-នៅពេលសវនាការនេះ កូនក្តីខ្ញុំឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់និងឈ្មោះ [redacted] ភារម្យ ហៅ រុំ បានឆ្លើយបញ្ជាក់ថាពុំបានប្រើប្រាស់អាវុធនោះទេ ដោយជនរងគ្រោះបានឆ្លើយបញ្ជាក់ជូនតុលាការរួចហើយនៅពេលសវនាការនេះ។ ចំពោះកូនក្តីខ្ញុំឈ្មោះ [redacted] ណើ ក៏មិនបានកាប់ទៅលើជនរងគ្រោះដែរ តែដោយស្មានតែចោរប្លន់ ទើបក្រវៀសដាវការពារខ្លួន ក៏ត្រូវសមត្ថកិច្ចតែម្តង។ ដូច្នេះសុំលោកចៅក្រមជំនុំជម្រះ អោយកូនក្តីខ្ញុំឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់ឈ្មោះ [redacted] ភារម្យ ហៅ រុំរួចខ្លួនពីបទចោទ និងបន្ធូរបន្ថយទោសដល់ឈ្មោះ [redacted] ណើ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ភារម្យ ហៅ រុំ និងឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់សុំឲ្យតុលាការលើកលែងចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] ណើ សុំអោយតុលាការបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចំលើយនិងអំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយ

## តុលាការយល់ឃើញថា:

-តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់ចៅក្រមស៊ើបសួរឃើញថាឈ្មោះ [redacted] សារ៉ា ហៅ រ៉ាត់ ភេទប្រុស អាយុ ២៥ឆ្នាំឈ្មោះ [redacted] ភារម្យ ហៅ រុំ ភេទប្រុស អាយុ២២ឆ្នាំ ឈ្មោះ [redacted] ណើ ភេទប្រុស អាយុ២៩ឆ្នាំត្រូវបញ្ជូនមកជំនុំជម្រះពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិដំណាក់អំពិល ឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលពីថ្ងៃទី ១៩

ខែ មេសា ឆ្នាំ២០១៨បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២១៨នៃក្រមព្រហ្មទណ្ឌ។

-តាមចំលើយជនជាប់ចោទឈ្មោះ [redacted] ណៃ ឆ្លើយថាខ្លួននិងបក្ខពួកខ្លួនមានបំណងទៅមើលល្ខោនដែលលេងនៅវត្តតាសិល្ប៍ ដោយសារផ្លូវទៅកាន់ទីនោះ មានបទល្មើសប្លន់កើតជាញឹកញាប់ ទើបពួកខ្លួនយកដាវដាក់តាមខ្លួនហើយខ្លួនមិនបានដឹងថាឈ្មោះ [redacted] ភារម្យ ហៅ រុំ និងឈ្មោះ [redacted] សាវ៉ា ហៅ វ៉ាត់យកថ្នាំញៀនទៅប្រគល់ឲ្យគេទេនៅពេលដែលបក្ខពួកខ្លួន បានស្រែកឲ្យជួយខ្លួនក៏ទៅជួយដោយមិននឹកស្មានថា ជាកំលាំងសមត្ថកិច្ចបង្ក្រាបបទល្មើសគ្រឿងញៀនឡើយ។ ក្រោយពីសមត្ថកិច្ចស្រែកថា គាត់ជាប៉ូលីសខ្លួនក៏ប្រគល់ខ្លួនឲ្យគាត់ចាប់តែម្តង។

-នៅពេលដែលចុះបង្ក្រាបបទល្មើសគ្រឿងញៀន សមត្ថកិច្ចមិនស្លៀកពាក់ឯកសណ្ឋានជានគរបាលទេ ហើយការបង្ក្រាបនោះធ្វើឡើងនៅពេលយប់ នៅទីកន្លែងស្ងាត់ដាច់ស្រយាលពីភូមិស្រុកស្រុក ធ្វើអោយជនជាប់ចោទភ័ណ្ឌច្រឡំថា មានអំពើប្លន់កើតឡើង ហើយដើម្បីការពារខ្លួននិងបក្ខពួករបស់ខ្លួនក៏បានដកដាវវាយបកលើក្រុមធ្វើសកម្មភាព (សមត្ថកិច្ច)។

-ទង្វើរបស់ជនជាប់ចោទមានបំណងត្រឹមតែការពារខ្លួនស្របច្បាប់តែប៉ុណ្ណោះ ប៉ុន្តែដោយជនជាប់ចោទប្រើដាវ ឯភាគីសមត្ថកិច្ចខណៈពេលបង្ក្រាបគ្មានអាវុធ ឃើញថាជនជាប់ចោទប្រព្រឹត្តសកម្មភាពហួសពីការការពារខ្លួនស្របច្បាប់។ ស្របតាមមាត្រា ៣៣,៣៤ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] សាវ៉ា ហៅ វ៉ាត់ ឈ្មោះ [redacted] ភារម្យ ហៅ រុំបានស្រែកឲ្យបក្ខពួកខ្លួនជួយខណៈដែលសមត្ថកិច្ចបង្ក្រាបគ្រឿងញៀនដោយមានការចាប់ឃាត់ខ្លួនអ្នកទាំងពីរនេះ ឃើញថាជនទាំងពីរនេះជាអ្នកផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ។

-អំពើរបស់ជនជាប់ចោទ ធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមហើយអំពើនេះស្របតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ា ឈ្មោះ [redacted] សេងហ៊្វរ បានប្តឹងសុំទាមទារសំណងថ្លៃថ្នាំព្យាបាលនិងជំងឺចិត្ត។ ចំពោះឈ្មោះ [redacted] គិត ឈ្មោះ [redacted] ម៉េងសែ មិនទាមទារសំណងនោះទេ។ ដូច្នេះតុលាការគប្បីពិនិត្យនិងពិចារណាតាមច្បាប់។

-វត្ថុតាងរួមមាន: ដាវចំនួន០២ដើម មិនមានប្រយោជន៍សំរាប់បំរើសង្គមជាតិឡើយ។ ដូច្នេះគប្បីត្រូវរឹបអូសបំផ្លាញចោល។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សាវ៉ា ហៅ វ៉ាត់ ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ឈ្មោះ [redacted] ភារម្យ ហៅ រុំ ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ណៃ ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិដំណាក់អំពិល



Scanned with CamScanner

ឃុំស្ពឹងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៨ តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

## **<u>វិនិច្ឆ័យសេចក្តី</u>**

១/ ផ្តន្ទាទោសលើឈ្មោះ [redacted] សារ៉ា ហៅរ៉ាត់ ភេទប្រុស អាយុ២៥ឆ្នាំជាតិខ្មែរ ឈ្មោះ [redacted] ភារម្យ ហៅរុំ ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល០២ឆ្នាំ (ពីរឆ្នាំ) តែអនុវត្តទោសក្នុងពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ (មួយឆ្នាំ) ទោសសល់ពីនេះអនុវត្តទោសព្យួរធម្មតា បន្តពីសាលក្រមលេខ ៨៨ (ក) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៨ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិដំណាក់អំពិល ឃុំស្ពឹងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៨ តាមមាត្រា ២១៨,១០៨ នៃក្រមព្រហ្មទណ្ឌ។

២/ផ្តន្ទាទោសលើឈ្មោះ [redacted] ណី ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារកំណត់រយៈពេល០២ឆ្នាំ (ពីរឆ្នាំ) តែអនុវត្តទោសក្នុងពន្ធនាគារកំណត់រយៈពេល០៤ខែ (បួនខែ) ទោសសល់ពីនេះអនុវត្តទោសព្យួរធម្មតា បន្តពីសាលក្រមលេខ ៨៨ (ក) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៨ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិដំណាក់អំពិល ឃុំស្ពឹងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៨តាមមាត្រា ២១៨, ១០៨ នៃក្រមព្រហ្មទណ្ឌ។

៣/ បង្គាប់ឲ្យឈ្មោះ [redacted]រ៉ា ហៅរ៉ាត់ ឈ្មោះ [redacted]ភារម្យ ហៅរុំ និងឈ្មោះ [redacted] ណី រួមគ្នាសងសំណងថ្លៃថ្នាំព្យាបាលឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ា ឈ្មោះ [redacted] សេងហ៊ួរ ក្នុងម្នាក់ៗចំនួន ១.០០០.០០០៛ (មួយលានរៀល) ការទាមទារលើសពីនេះបដិសេធចោល។

៤/ វត្ថុតាងរួមមាន: ដាវចំនួន០២ដើម ត្រូវរឹបអូសបំផ្លាញចោល។

៥/សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ា ហៅរ៉ាត់ ឈ្មោះ [redacted] ភារម្យ ហៅរុំ ឈ្មោះ [redacted] ណី ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ា និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]គិត ឈ្មោះ [redacted] ម៉េងសៃ ឈ្មោះ [redacted] សេងហ៊ួរ បើកសិទ្ធិឲ្យប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| **ហត្ថលេខានិងត្រា** | **ហត្ថលេខានិងត្រា** |
| លោក [redacted] | លោក [redacted] |

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ០៥កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅកំពង់ចាម ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៩

**ក្រឡាបញ្ជី**